**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខៈ១៣៩០ អយក.ហវ**

ថ្ងៃសុក្រ ១១កើត ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែ២ ឆ្នាំ២០១៩

**ជម្រាបមក**

- **លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**
- **លោក លោកស្រី ប្រធានការិយាល័យអប់រំ ក្រុង ស្រុក ខណ្ឌ**
- **លោក លោកស្រី នាយក នាយិកាគ្រឹះស្ថានមត្តេយ្យសិក្សានិងចំណេះទូទៅសាធារណៈ**

**កម្មវត្ថុ ៖** ការដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងមូលនិធិដំណើរការសាលារៀន(SOF) នៅតាមគ្រឹះស្ថានសិក្សាសាធារណៈ ការិយាល័យអប់រំ ក្រុង ស្រុក ខណ្ឌ និងមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្តចាប់ពីឆ្នាំ២០១៩ តទៅ ។

**យោង ៖** -លិខិតលេខ៣០៦៥ អយក.ហវ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨ របស់ក្រសួងអប់រំ យុវជន និងកីឡា
-លិខិតលេខ២៤៣ សហវ.អថ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៩ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **លោក លោកស្រីប្រធាន នាយក នាយិកា** ជ្រាបថាៈ កាលពីឆ្នាំ២០១៨ កន្លងមកក្រសួងអប់រំ យុវជន និងកីឡា បានដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រោងថវិកាដំណើរការសាលារៀននិងរបាយការណ៍ហិរញ្ញវត្ថុ នៅតាមគ្រឹះស្ថានសិក្សាសាធារណៈ ការិយាល័យអប់រំ ក្រុង ស្រុក ខណ្ឌ និងមន្ទីរអប់រំយុវជន និងកីឡារាជធានី ខេត្ត តាមស្មារតីនៃលិខិតលេខ៣០៦៥ អយក.ហវ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨ ។ ដោយឡែក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏បានឯកភាពផ្តល់ថវិកាចំនួន **៤ ០៥០ ០០០រៀល** (បួនលានហាសិបពាន់រៀលគត់) ជូនគ្រប់សាលារៀនសាធារណៈទូទាំងប្រទេសសម្រាប់ទិញសម្ភារបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា(កុំព្យូទ័រ១គ្រឿងនិងព្រីនធ័រ១គ្រឿង) ដើម្បីប្រើប្រាស់ជាប្រយោជន៍ក្នុងកិច្ចដំណើរការអង្គភាព ជាពិសេសពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុ ប្រកបដោយតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព ព្រមទាំងអនុញ្ញាតជាគោលការណ៍ ឲ្យប្រើប្រាស់សៀវភៅគោលការណ៍ណែនាំ ស្តីពីការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ ចាប់ពីឆ្នាំ២០១៩ តទៅ តាមលិខិតលេខ១០០៤៣ សហវ.អថ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៨ ។

ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើបច្ចុប្បន្នភាពប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រោងថវិកានិងរបាយការណ៍ហិរញ្ញវត្ថុ ដោយបានពង្រីកវិសាលភាពមុខងារនៃការប្រើប្រាស់ក្នុងប្រព័ន្ធកាន់តែមានភាពទូលំទូលាយនិងប្រសើរជាងមុន ហើយបន្សុីជាមួយនឹងគោលការណ៍ណែនាំ ស្តីពីការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ ដោយបានឆ្លុះបញ្ចាំងថវិកាគ្រប់ប្រភព(ថវិការដ្ឋ ដៃគូ សហគមន៍ និងប្រភពផ្សេងៗ) ជាពិសេសពាក់ព័ន្ធនឹងការគ្រោងថវិកាមានភាពច្បាស់លាស់



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទៈ (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារៈ (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែលៈ info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

និងចំមុខសញ្ញាចំណាយជាក់ស្តែងសម្រាប់អភិវឌ្ឍន៍សាលារៀន ស្របតាមកម្មវិធីកែទម្រង់វិស័យអប់រំដែលជាចំណុចអាទិភាពចម្បង គឺការអភិវឌ្ឍធនធានមនុស្សប្រកបដោយចីរភាព និងបង្កើនមូលធនបញ្ញានៅកម្ពុជាជាកាលានុវត្តភាពនៃការប្រកួតប្រជែងសេដ្ឋកិច្ចនិងទីផ្សារការងារបច្ចុប្បន្ន។ ដូចនេះ ក្រសួងផ្តល់ជូននូវប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ប្រើប្រាស់ក្នុងការគ្រប់គ្រងមូលនិធិដំណើរការសាលារៀន(SOF) ដែលមានលក្ខណៈបច្ចេកវិទ្យានិងស្តង់ដាររួមទូទាំងប្រទេសដល់គ្រឹះស្ថានសិក្សាសាធារណៈ ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត សម្រាប់ដាក់ឲ្យអនុវត្តជាផ្លូវការចាប់ពីឆ្នាំ២០១៩ តទៅ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោក លោកស្រីប្រធាន នាយក នាយិកា** ចូលរួមចាត់ចែង ផ្សព្វផ្សាយ និងអនុវត្តឲ្យបានទូលំទូលាយនិងមានប្រសិទ្ធភាពខ្ពស់។

សូម **លោក លោកស្រីប្រធាន នាយក នាយិកា** ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ ។

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**ចម្លងជូន៖**
- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
  " ដើម្បីជ្រាបជាព័ត៌មាន "
- កាលប្បវត្តិ
- ឯកសារ នាយកដ្ឋានហិរញ្ញវត្ថុ

បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន